ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០២១/២៣-បូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីធីត
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៣

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ អ៊ឹង សុទ្ធី
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ លីវ សុវណ្ណា
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ ប៉ែន ប៊ុនឈា

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីធីត**
អាសយដ្ឋាន ៖ ភូមិពងទឹក ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល
ទូរស័ព្ទ ៖ ០១៧ ៦៦៦ ៨២១ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជកចូលរួមសវនាការ ៖

- លោក សរ ប្រធានជាន់ខ្ពស់គ្រប់គ្រងផ្នែកធនធានមនុស្ស

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ **ភាគីតំណាងកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីធីត**
អាសយដ្ឋាន ៖ ភូមិពងទឹក ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល
ទូរស័ព្ទ ៖ ០១២ ៤៨៤ ៥៨៣ /០១២ ៥៧៦ ៤៩៥ ទូរសារ ៖ គ្មាន
តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការ ៖

១- លោក ពសអ មន្ត្រីផ្នែកច្បាប់មជ្ឈមណ្ឌលអាមេរិកាំងសម្រាប់សាមគ្គីភាពការងារអន្តរជាតិ (ACILS)
២- លោក វសណ ប្រធានសហព័ន្ធសហជីពឯករាជ្យ (INTUFE)
៣- លោក ឡសភ ប្រធានសហជីពកម្ពុជា
៤- លោក សគស លេខាសហជីពកម្ពុជា
៥- លោក ឈច តំណាងកម្មករ

ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥.២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Toul Kork, Phnom Penh + Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org + Website: www.arbitrationcouncil.org

៦- លោក ខខ តំណាងកម្មករ

៧- លោក នវច តំណាងកម្មករ

៨- លោកស្រី សច តំណាងកម្មករ

៩- លោកស្រី មគ តំណាងកម្មករ

១០-លោក សឃទ តំណាងកម្មករ

១១- លោក អខ ទីប្រឹក្សាសហព័ន្ធ

១២- លោក សច ប្រធានសហសេរីឯករាជ្យ

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ចំណុចទាមទារទី១ ស្នើសុំក្រុមហ៊ុនរៀបចំកម្មករថែមម៉ោង តាមគោលការណ៍ស្ម័គ្រចិត្ត និងអនុវត្តតាមគោលការណ៍ចាស់(ដូចមុន)។

ភាគីតំណាងកម្មករនិយោជិតបានបញ្ជាក់ថា៖

-នៅពេលក្រុមហ៊ុនមានការងារថែមម៉ោង គឺបានសួរនាំ និងឱ្យកម្មករចុះហត្ថលេខាស្ម័គ្រចិត្តដោយផ្ទាល់នៅលើលិខិតថែមម៉ោង។

-ចំពោះកម្មករដែលបានថែមម៉ោង ទាល់តែដេរគ្រប់ចំនួនកំណត់ ហើយការថែមនេះ គិតចាប់ពីខែសីហា ឆ្នាំ២០២៣ មានប្រហែលជា ៥០% ក្នុងចំនួនកម្មករសរុបដែលបានធ្វើការងារ។

-ករណីកម្មកររូបណាធ្វើការពុំសូវល្អ និងដេរមិនគ្រប់ចំនួនកំណត់ នោះពុំសូវបានធ្វើការបន្ថែមម៉ោងនោះទេ។

-ពាក់ព័ន្ធការថែមម៉ោងនេះ ស្នើសុំឱ្យក្រុមហ៊ុនអនុវត្តតាមគោលការណ៍ចាស់ ដោយចុះហត្ថលេខាថែមម៉ោងនៅក្នុងថ្ងៃតែមួយ។ ដោយឡែក ភាគីតំណាងក្រុមហ៊ុនបញ្ជាក់ថា នៅពេលមានសម្ភារៈធ្វើគ្រប់គ្រាន់ ហើយមានការងារធ្វើត្រូវបន្ថែមម៉ោងក្នុងខ្សែច្រវាក់ផលិតកម្ម គឺក្រុមហ៊ុនរៀបចំចាត់ចែងនៅផ្នែកដែលចាំបាច់នោះ និងផ្អែកតាមគោលការណ៍ស្ម័គ្រចិត្តចូលរួមពីកម្មករនិយោជិត ហើយក្រុមហ៊ុននឹងទូទាត់អត្ថប្រយោជន៍បន្ថែមជូនតាមច្បាប់។ ករណីមានការធ្វើការបន្ថែមម៉ោងនៅតាមក្រុម ឬផ្នែកចាំបាច់ នោះក្រុមហ៊ុននឹងជូនដំណឹងឱ្យបានមុនតាមក្រុម និងផ្នែកនោះដោយស្ម័គ្រចិត្តចូលរួមសហការ និងធ្វើការដោយគ្មានការបង្ខិតបង្ខំទេ។ ចំពោះការស្ម័គ្រចិត្តថែមម៉ោងដែលក្រុមហ៊ុនបានរៀបចំផ្តល់ជូនកម្មករនិយោជិតនោះ ហើយប្រសិនមានប្រធានក្រុម ឬប្រធានផ្នែកណាប្រើអាកប្បកិរិយា ឬពាក្យសម្តីមិនសមរម្យមកលើកម្មករ នៅពេលមានកម្មករសុំច្បាប់ ឬមានធុរៈសុំចេញមុន នោះក្រុមហ៊ុននឹងពិនិត្យណែនាំសាមីខ្លួនតាមការជាក់ស្តែង ដោយជូនដំណឹងមកតាមគណៈគ្រប់គ្រងក្រុមហ៊ុន ដើម្បីពិនិត្យ និងចាត់វិធានការតាមបទបញ្ជាផ្ទៃក្នុង និងច្បាប់ជាធរមាន។

២- ចំណុចទាមទារទី២ ស្នើសុំក្រុមហ៊ុនបើកប្រាក់ថ្លៃបាយ មួយសប្តាហ៍ម្តង រាល់រៀងចុងសប្តាហ៍។

ភាគីតំណាងកម្មករនិយោជិតបានបញ្ជាក់ថា៖

-បច្ចុប្បន្នក្រុមហ៊ុនបានបើកប្រាក់ថ្លៃបាយថ្ងៃត្រង់ និងប្រាក់ថ្លៃបាយបន្ថែមម៉ោងជូនកម្មករនិយោជិតនៅរៀងរាល់ចុងសប្តាហ៍ ប៉ុន្តែមានការយឺតយ៉ាវ ធ្វើឱ្យពិបាកដល់កម្មករនៅពេលទៅបើកប្រាក់។

-កម្មករបញ្ជាក់ថា ការបើកប្រាក់តាមប្រព័ន្ធធនាគារជាលក្ខណៈល្អប្រសើរ និងមិនមានការជំទាស់អ្វីនោះទេ។

-ស្នើសុំនិយោជកចេញមុនម៉ោងចំនួន ១០នាទី នៅថ្ងៃបើកប្រាក់ឈ្នួល ព្រោះកម្មករត្រូវចំណាយពេលតម្រង់ជួរពេលចប់ម៉ោងការងារ ដោយខុសពីការបើកប្រាក់ផ្ទាល់ ដោយពួកគាត់ត្រូវចំណាយពេលបន្ថែមពេលចាប់ពី ២០នាទី ទៅ៤០នាទី ក្នុងពេលបើកប្រាក់ថ្លៃបាយម្ដងៗ។ ដោយឡែក ភាគីតំណាងក្រុមហ៊ុនបញ្ជាក់ថា ចំណុចនេះ ក្រុមហ៊ុនបានអនុវត្តបើកផ្ដល់ជូនកម្មករនិយោជិតរួចរាល់ហើយ ផ្អែកតាមកំណត់ហេតុផ្សះផ្សាចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២២ ត្រង់ចំណុចសះជាទី២ ទី៣ និងទី៤ ដោយក្រុមហ៊ុនបានអនុវត្ត និងជួយសម្រួលបើកប្រាក់ថ្លៃបាយបន្ថែមម៉ោង ក្នុងការបំពេញការងារ (OT) ក៏ដូចជាប្រាក់ថ្លៃបាយបន្ថែមម៉ោង វេនថ្ងៃ ជូនកម្មករនិយោជិតនៅរៀងរាល់ថ្ងៃសុក្រ (មិនមានការយឺត ដូចការលើកឡើងរបស់តំណាងកម្មករ) ដើម្បីជួយសម្រួលដល់កម្មករនិយោជិតទាំងអស់បានបើកថវិកានោះ សម្រាប់ទុកចាត់ចែងប្រើប្រាស់ ដើម្បីផ្គត់ផ្គង់ជីវភាព និងបំពេញតម្រូវការចាំបាច់ប្រចាំថ្ងៃរបស់ខ្លួនបាន ក៏ដូចជាការចាយវាយក្នុងការទិញនំនែក ត្រី សាច់សម្រាប់បរិភោគ។ ក្នុងករណីពិសេស ប្រសិនការបើកប្រាក់នោះចំថ្ងៃសៅរ៍ នោះក្រុមហ៊ុន និងជូនដំណឹង ឬរក្សាការបើកប្រាក់ទាំងនោះនៅថ្ងៃសៅរ៍ដដែល ដើម្បីសម្រួលការទំលាក់លុយចូលកុងធនាគារក្នុងថ្ងៃតែមួយ។

៣- ចំណុចទាមទារទី៣ ស្នើសុំក្រុមហ៊ុនចេញមុនម៉ោងចំនួន ១០នាទី រៀងរាល់ថ្ងៃបើកប្រាក់ឈ្នួល ក្នុងករណីមិនឯកភាពគ្នា សុំបើកប្រាក់ដោយផ្ទាល់តាមច្បាប់ស្ដីពីការងារ។

ភាគីតំណាងកម្មករនិយោជិតបានបញ្ជាក់ថា៖

-បច្ចុប្បន្ន រាល់ពេលប្រាក់ឈ្នួលរបស់កម្មករនិយោជិតចូលក្នុងកុងធនាគារម្ដងៗ ទាល់តែដល់ម៉ោងចេញពីធ្វើការងារ ទើបកម្មករនិយោជិតអាចទៅបើកប្រាក់ឈ្នួល ត្រូវចំណាយពេលបន្ថែមពេលចាប់ពី ២០នាទី ទៅ ៤០នាទី ក្នុងពេលបើកប្រាក់ថ្លៃបាយម្ដងៗ ឬធ្វើដំណើរទៅកាន់ធនាគារ ដើម្បីបើកប្រាក់ឈ្នួលនោះតែម្ដង។ ដោយនៅថ្ងៃប្រាក់ចូលកុងធនាគារ កម្មករនិយោជិតមកដកប្រាក់មានការកកស្ទះ ធ្វើឱ្យការដកប្រាក់មានភាពយឺតយ៉ាវ ហើយកម្មករត្រូវជិះឡានឈ្នួលទៅផ្ទះឆ្ងាយ (ពេលខ្លះឡានចេញទៅចោលកម្មករ) ដូច្នេះ បងប្អូនកម្មករនិយោជិតត្រូវចំណាយប្រាក់បន្ថែមលើការជិះឡានឈ្នួល និងបន្តជិះម៉ូតូឌុបទើបដល់ផ្ទះ។ ករណីនេះ ស្នើសុំឱ្យក្រុមហ៊ុនជួយសម្រួលឱ្យកម្មករបានចេញមុនម៉ោងចំនួន ១០នាទី រៀងរាល់ថ្ងៃបើកប្រាក់ឈ្នួល។

-ស្នើសុំនិយោជកចេញមុនម៉ោង ១០នាទី នៅថ្ងៃបើកប្រាក់ឈ្នួលព្រោះកម្មករត្រូវចំណាយពេលតម្រង់ជួរពេលចប់ម៉ោងការងារ ដោយខុសពីការបើកប្រាក់ផ្ទាល់ ដោយពួកគាត់ត្រូវចំណាយពេលបន្ថែមទៀត។

-កន្លងមក ក្រុមហ៊ុនបានបើកប្រាក់ឈ្នួលជូនកម្មករនិយោជិត នៅរៀងរាល់ថ្ងៃទី០៩ និងថ្ងៃទី២៤។

ដោយឡែក ភាគីតំណាងក្រុមហ៊ុនបញ្ជាក់ថា ត្រង់ចំណុចនេះ ក្រុមហ៊ុនបានបើកប្រាក់ឈ្នួលជូនកម្មករនិយោជិតផ្អែកតាមនីតិវិធីច្បាប់ ក្នុង ១ខែ ២ដង (គឺផ្ទេរប្រាក់ចូល នៅថ្ងៃទី២៤ ក្នុងខែ និងថ្ងៃទី០៩ នៃខែបន្ទាប់) ដូចមានចែងក្នុងប្រការ៧ អំពីប្រាក់ឈ្នួល នៃអនុសញ្ញារួមដែលបានចុះជាមួយសហជីពដែលមានភាពជាតំណាងបំផុត។ ជាមួយគ្នានេះ ក្រុមហ៊ុនក៏បានជួយសម្របសម្រួលបន្ថែមក្នុងការបើកប្រាក់ថ្លៃបាយថ្ងៃត្រង់ ៣០០០រៀល និងប្រាក់ថ្លៃបាយសម្រាប់កម្មករនិយោជិតបានធ្វើការបន្ថែមម៉ោង ៣០០០រៀលទៀត ដោយសរុបបើកជូននៅរៀងរាល់ថ្ងៃសុក្រក្នុងសប្ដាហ៍នីមួយៗ។

ចំពោះការស្នើសុំចេញមុនម៉ោងទៅបើកប្រាក់ឈ្នួល ក្រុមហ៊ុនមិនអាចផ្ដល់ជូនបានទេ។ ទន្ទឹមនឹងនេះ រាល់ការបើកប្រាក់ឈ្នួល និងបើកប្រាក់អត្ថប្រយោជន៍ផ្សេងៗទាំងនោះ គឺធ្វើឡើងដោយទៀងទាត់ជាប្រចាំ។ ក្នុងករណីការបើកប្រាក់នោះចំថ្ងៃបុណ្យ ឬថ្ងៃអាទិត្យ ក្រុមហ៊ុននឹងរៀបចំបើកឱ្យបានមុន ១ថ្ងៃ ហើយការបើក

ប្រាក់នោះតាមប្រព័ន្ធធនាគារ គឺជាការអនុវត្តល្អប្រសើរតាមគោលការណ៍ណែនាំ និងនីតិវិធីច្បាប់។ ម្យ៉ាងទៀត ការបើកប្រាក់តាមប្រព័ន្ធធនាគារនេះ កម្មករនិយោជិត ក៏មិនជំទាស់អ្វីនោះដែរ។ ព្រោះការបើកតាមវិធីនេះ វាមានលក្ខណៈសុក្រឹត និងត្រឹមត្រូវ ដោយមិនធ្វើឱ្យប៉ះពាល់ផល ឬបាត់បង់ប្រយោជន៍របស់ភាគីណាមួយឡើយ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៨៥/២០ ក.ប/ប្រ.ក.វ. ក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ (អាណត្តិទី១៨)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូ-ឌា) ខមភេនី លីមីធីត លេខ ៦៤៤ ក.ប/អក/វក ចុះថ្ងៃពុធ ៤កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៣ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២៣។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃអង្គារ ២រោច ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៣ វេលាម៉ោង ២ និង ០០ នាទី រសៀល។

**បញ្ហានីតិវិធី ៖**

នៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២៣ នាយកដ្ឋានវិវាទការងារ បានទទួលពាក្យបណ្តឹងរបស់ភាគីកម្មករនិយោជិតនៃក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីធីត ស្នើសុំឱ្យក្រុមហ៊ុនដោះស្រាយការទាមទារចំនួន ៣ចំណុច។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងនេះរួចមក នាយកដ្ឋានវិវាទការងារ បានចាត់មន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងារនេះជាបន្តបន្ទាប់ និងបានធ្វើការផ្សះផ្សា នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣ ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នានោះទេ។ ចំណុចមិនសះជានេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញា-កណ្តាលនៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២៣ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីធីត លេខ ៦៤៤ ក.ប/អក/វក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៣។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៣។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងផ្សះផ្សាលើករណីមិនសះជានេះ នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៣ វេលាម៉ោង ១៤ និង ០០

នាទីរសៀល។ ភាគីទាំងពីរមានវត្តមាននៅក្នុងសវនាការ តាមការអញ្ជើញរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមស្វះរកនូវអង្គហេតុផ្សេងៗ ដែលទាក់ទងទៅនឹងចំណុចវិវាទមិនសះជាចំនួន ៣ចំណុចនេះ និងបានផ្សះផ្សាលើចំណុចវិវាទនេះបន្ថែមទៀត ដោយភាគីទាំងពីរបានព្រមព្រៀងគ្នាចំនួន ១ចំណុច គឺចំណុចវិវាទទី១ ហើយភាគីកម្មករនិយោជិតបានដកចំណុចវិវាទទី៣ ចេញពីសំណុំរឿងនេះ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាលើចំណុចវិវាទដែលនៅសល់ គឺចំណុចវិវាទទី២។

នៅក្នុងសំណុំរឿងនេះ ភាគីជ្រើសរើសសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាល បានកំណត់ថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២៣ ជាថ្ងៃផុតកំណត់ផ្តល់ឯកសារ ឬភស្តុតាង និងថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២៣ ជាថ្ងៃផុតកំណត់ជំទាស់ឯកសារ ឬភស្តុតាង។

ភាគីទាំងពីរឯកភាពពន្យារកាលបរិច្ឆេទនៃការចេញសេចក្តីបង្គាប់អាជ្ញាកណ្តាល ពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣ ទៅយ៉ាងយូរ ត្រឹមថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៣ វិញ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

## ភស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

## ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលទទួលបាន

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- លិខិតផ្ទេរសិទ្ធិចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២៣ របស់លោក Michael Khor ជានាយកសហគ្រាស ប៊ូវយើរ ហ្វាមេន ហ្វេកជើរី (ខេមបូឌា) ខមភេនី លីមីធីត គោរពជូន លោកប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើសុំផ្ទេរសិទ្ធិជូនលោក ជាតំណាងក្រុមហ៊ុន ដែលមានសិទ្ធិ និងអំណាចពេញលេញក្នុងការដោះស្រាយរាល់បញ្ហាវិវាទការងារ ក្នុងនាមតំណាងឱ្យម្ចាស់ ឬនាយកក្រុមហ៊ុន ព្រមទាំងមានសិទ្ធិសម្រេចរាល់កិច្ចព្រមព្រៀងផ្សេងៗផងដែរ ដើម្បីទំនាក់ទំនងជាមួយក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងករណីវិវាទរួម នៅសហគ្រាស យីហោ ប៊ូវយើរ ហ្វាមេន ហ្វេកជើរី (ខេមបូឌា) ខមភេនី លីមីធីត ក្នុងសំណុំរឿងលេខ ០២១/២៣។

២- លិខិតចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២៣ របស់តំណាងនិយោជកក្រុមហ៊ុន ប៊ូវយើរ ហ្វាមេន ហ្វេកជើរី (ខេមបូឌា) ខមភេនី លីមីធីត សូមគោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីការផ្តល់ជូនសារណាសង្ខេបស្តីពីសំណុំរឿងលេខ ០២១/២៣។

៣- សេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស ប៊ូវយើរ ហ្វាមេន ហ្វេកជើរី (ខេមបូឌា) ខមភេនី លីមីធីត DE20210635 អធក ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២១។

៤- លក្ខន្តិកៈរបស់ក្រុមហ៊ុន ប៊ូវយើរ ហ្វាមេន ហ្វេកជើរី (ខេមបូឌា) ខមភេនី លីមីធីត បានតម្កល់ទុកលេខ ២០១៤/២០១២ ពណ.ចបព ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១២ នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម។

៥- អនុសញ្ញារួមនៃការងារ រវាងសហជីពអព្យាក្រឹត្យអភិវឌ្ឍន៍ការងារ ជាសមាជិកសហព័ន្ធអំណាចកម្មករខ្មែរ (KWPFU) សហជីពកម្មករកម្ពុជា ជាសមាជិកសហព័ន្ធសហជីពកម្មករកម្ពុជា (CLUF) សហជីពពលកម្មកម្ពុជា ជាសមាជិកសហព័ន្ធសហជីពពលកម្មកម្ពុជា (CFLU) ជាមួយក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកជើរី (ខេមបូឌា) ខមភេនី លីមីធីត អាណត្តិទី០១ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៣ ដល់ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៦ បានចុះបញ្ជីកាលេខ ០៥២/កប/អក/វក ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៣ ដោយនាយកដ្ឋានវិវាទការងារ។

៦- វិញ្ញាបនបត្របញ្ជាក់ពីភាពជាតំណាងបំផុត របស់សហជីពអព្យាក្រឹត្យអភិវឌ្ឍន៍ការងារ ក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកជើរី (ខេមបូឌា) ខមភេនី លីមីធីត លេខ ២៩៧/២១ កប/វបវក ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១។

៧- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួម នៃក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកជើរី (ខេមបូឌា) ខមភេនី លីមីធីត ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២២។

៨- បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកជើរី (ខេមបូឌា) ខមភេនី លីមីធីត បានចុះទិដ្ឋាការលេខ ១៩៦៧/១៨ ក.ប.វ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៨ ដោយមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល។

៩- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួម នៃក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកជើរី (ខេមបូឌា) ខមភេនី លីមីធីត ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣។

១០- កិច្ចសន្យាការងារដែលមានកំណត់ថិរវេលាកំណត់រវាងក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកជើរី (ខេមបូឌា) ខមភេនី លីមីធីត និងឈ្មោះ ស៊ឹម កែវ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២២។

១១- លិខិតចុះថ្ងៃទី០៣ ខែកម្ភៈ ឆ្នាំ២០២២ របស់ក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកជើរី (ខេមបូឌា) ខមភេនី លីមីធីត សូមគោរពជូន ឯកឧត្តមរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ស្តីពីសំណើសុំផ្តល់របាយការណ៍ និងបន្តសុពលភាពរបស់ក្រុម មួយឆ្នាំទៀត តាមប្រកាសលេខ ២៣២ ព.ណ.បអព ប្រក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៣ របស់ក្រសួងពាណិជ្ជកម្ម។

១២- តារាងវត្តមានការងាររបស់ឈ្មោះ ខឿន មករា។

១៣- ឯកសារជាប្រតិទិនខែកញ្ញា និងខែតុលា។

១៤- ឯកសារបញ្ជីប្រាក់ឈ្នួលរបស់ក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកជើរី (ខេមបូឌា) ខមភេនី លីមីធីត តាមគណនីយធនាគារអេស៊ីលីដា។

១៥- ឯកសារការវេលុយថ្លៃបាយចូលក្នុងកុងធនាគាររបស់កម្មករនិយោជិតពីរដងដែលឆ្លងខែ(ខែចាស់ និងខែថ្មី)ចូលក្នុងថ្ងៃតែមួយ។

១៦- ឯកសារជារូបភាពម៉ាស៊ីនអេធីអឹម។

១៧- ឯកសារជាភាសាបរទេស។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖

១- លិខិតលេខ ០៤៣/២៣ ACILS ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣ របស់មជ្ឈមណ្ឌលអាមេរិកកាំងសម្រាប់សាមគ្គីភាពការងារអន្តរជាតិ (ACILS) សូមគោរពជូន ប្រធានលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីចាត់តាំងឈ្មោះ ពសអ មន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់ ចូលរួមដោះស្រាយសំណុំរឿងវិវាទការងាររួមលេខ ០២១/២៣ នៃក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីធីត។

២- លិខិតលេខ ០៥២/២៣ ស.ស.ឯ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៣ របស់សហព័ន្ធសហជីពឯករាជ្យ គោរពជូន វលខ នាយកមជ្ឈមណ្ឌលអាមេរិកកាំងសម្រាប់សាមគ្គីភាពការងារអន្តរជាតិ ស្តីពីសំណើរសុំចាត់តាំងលោក ពសអ មន្ត្រីផ្នែកច្បាប់ ដើម្បីជួយអម និងធ្វើជាអ្នកតំណាងសិទ្ធិ ឱ្យកម្មករនិយោជិត។

៣- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួម នៃក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីធីត ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣។

៤- ពាក្យបណ្តឹងចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២៣ របស់កម្មករនិយោជិតបម្រើការងារនៅក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីធីត គោរពជូន ប្រធាននាយកដ្ឋានវិវាទការងារ ស្តីពីស្នើសុំលោកប្រធានជួយដោះស្រាយលក្ខខណ្ឌការងារមួយចំនួន។

៥- ញត្តិគាំទ្រ របស់កម្មករនិយោជិតបំរើការងារនៅក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីធីត។

៦- លិខិតផ្ទេរសិទ្ធិរបស់កម្មករនិយោជិតនៃក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីធីត សូមប្រគល់សិទ្ធិឱ្យឈ្មោះ អខ ភេទប្រុស តួនាទីជាទីប្រឹក្សាសហព័ន្ធសហជីពសេរីឯករាជ្យ ចូលរួមផ្សះផ្សាវិវាទរបស់យើងខ្ញុំចំនួន ៣ចំណុច នៅក្រុមប្រឹក្សាអាជ្ញាកណ្តាលថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៣ វេលាម៉ោង ១៤:០០ នាទី។

៧- លិខិតលេខ ១៤១ ក.ប/អក/វក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២៣ របស់នាយកដ្ឋានវិវាទការងារ ជម្រាបមកលោកស្រីប្រធានសហជីពសេរីឯករាជ្យ នៃក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូ-ឌា) ខមភេនី លីមីធីត ស្តីពីការស្នើសុំទទួលស្គាល់ថ្នាក់ដឹកនាំសហជីពអាណត្តិទី២។

៨- វិញ្ញាបនបត្រចុះបញ្ជីអង្គការវិជ្ជាជីវៈសហជីពសេរីឯករាជ្យ នៃក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា)ខមភេនី លីមីធីត លេខ ២៧៧/២១ ក.ប/វប.វក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១។

៩- លិខិតចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់តំណាងកម្មករនិយោជិត គោរពជូន ប្រធានលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីជូនសារណានៃក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូ-ឌា)ខមភេនី លីមីធីត។

១០- លិខិតចុះថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់តំណាងកម្មករនិយោជិត គោរពជូន ប្រធានលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីបដិសេធឯកសារភស្តុតាង និងទទួលស្គាល់ការឆ្លើយតបរបស់ក្រុមហ៊ុន ចុះថ្ងៃទី៣១ ខែតុលា និងថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២៣។

ARBITRATION COUNCIL

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ៖

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូ-ឌា) ខមភេនី លីមីធីត លេខ ៦៤៤ ក.ប/អក/វក ចុះថ្ងៃពុធ ៤កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៣។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៃក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីធីត ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣។

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីធីត លេខ ០០៣/២០២៣ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៣ របស់នាយកដ្ឋានវិវាទការងារ។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ៖

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ១០៩ កប/អក/វក/លកអ ចុះថ្ងៃអង្គារ ១០កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៣។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ១១០ កប/អក/វក/លកអ ចុះថ្ងៃអង្គារ ១០កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៣។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖

- ក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីធីត មានសកម្មភាពចម្បងផ្នែក កាត់ដេរសម្លៀកបំពាក់ និងមានជួលកម្មករនិយោជិតសរុបចំនួន ៤២៨៩នាក់។ *(យោងតាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីធីត លេខ ៦៤៤ ក.ប/អក/វក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៣)*
- នាយកដ្ឋានវិវាទការងារ បានចេញលិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមលេខ ០០៣/២០២៣ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៣ ដែលមានកម្មករនិយោជិតចំនួន ៨នាក់ រួមមាន ៖ ១. ឡស ២. ឈច ៣. នវច ៤. សចណ ៥. សគស ៦. សឃរ ៧. សច ៨. មគទ ។
- សហជីពអព្យាក្រឹត្យអភិវឌ្ឍន៍សិទ្ធិការងារនៃរោងចក្រ បូវយើរ ហ្គាមេន ហ្វេកធើរី ខេមបូឌា ខមភេនី លីមីធីត ទទួលបានវិញ្ញាបនបត្របញ្ជាក់ភាពជាតំណាងបំផុត ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈលេខ ២៩៧/២១ ក.ប/វ.ប.វ.ក ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១។

ចំណុចវិវាទទី២ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកបើកប្រាក់ថ្លៃបាយ មួយសប្តាហ៍ម្តង រាល់រៀងចុងសប្តាហ៍

- ភាគីកម្មករនិយោជិតបញ្ជាក់ការទាមទារ ឱ្យនិយោជកបើកប្រាក់ថ្លៃបាយថ្ងៃត្រង់ និងប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង មួយសប្តាហ៍ម្តង រៀងរាល់ថ្ងៃសុក្រ និងបើកដោយផ្ទាល់ដៃជូនកម្មករនិយោជិត។

- ភាគីទាំងពីរទទួលស្គាល់ថា ៖
    - និយោជកធ្លាប់អនុវត្តការបើកប្រាក់ថ្លៃបាយថ្ងៃត្រង់ និងប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងជូនកម្មករនិយោជិតដោយផ្ទាល់ដៃ ចាប់តាំងពីពេលបង្កើតក្រុមហ៊ុននៅឆ្នាំ២០១៣ រហូតដល់ខែមេសា ឆ្នាំ២០២១។
    - បច្ចុប្បន្ននេះ ក្រុមហ៊ុនអនុវត្តបើកប្រាក់ថ្លៃបាយថ្ងៃត្រង់ និងប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងជូនកម្មករនិយោជិតរៀងរាល់ថ្ងៃសុក្រ តាមរយៈគណនីធនាគារ អេស៊ីលីដា។
- ភាគីកម្មករនិយោជិតបានបញ្ជាក់មូលហេតុនៃការទាមទារថា ៖
    - កម្មករនិយោជិតមិនបានយល់ស្របឱ្យនិយោជកបើកប្រាក់ថ្លៃបាយថ្ងៃត្រង់ និងប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងតាមគណនីធនាគារនោះទេ ប៉ុន្តែដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ ទើបកម្មករនិយោជិតយល់ព្រមបើកតាមគណនីធនាគារសិន។
    - កម្មករនិយោជិតបានព្រមព្រៀងផ្ទាល់មាត់ជាមួយនិយោជកក្នុងការផ្លាស់ប្តូរបើកប្រាក់ថ្លៃបាយថ្ងៃត្រង់ និងប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងដោយផ្ទាល់ដៃ មកជាការបើកតាមគណនីធនាគារ កាលពីខែមេសា ឆ្នាំ២០២១ គឺដោយសារនិយោជកបានសន្យាថានឹងផ្លាស់ប្តូរទៅបើកដោយផ្ទាល់ដៃវិញនៅពេលចប់ការរីករាលដាលនៃជំងឺកូវីដ-១៩។
    - នៅឆ្នាំ២០២២ កម្មករនិយោជិតនៅតែជំទាស់នឹងការបើកប្រាក់ថ្លៃបាយថ្ងៃត្រង់ និងប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងតាមគណនីធនាគារ ប៉ុន្តែមន្ត្រីផ្សះផ្សារបស់ក្រសួងការងារបានផ្សះផ្សា និងបានលើកឡើងអំពីបញ្ហាជំងឺកូវីដ-១៩ នៅមិនទាន់ធូរស្បើយ ទើបណែនាំឱ្យកម្មករនិយោជិតរង់ចាំដេញដោលគ្នានៅពេលក្រោយ។
    - ចំពោះការបើកប្រាក់ថ្លៃបាយថ្ងៃត្រង់ និងប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងដោយផ្ទាល់ដៃ គឺជួយសម្រួលដល់កម្មករនិយោជិតក្នុងការយកទៅចំណាយផ្សេងៗ។
    - កម្មករនិយោជិតពិបាកដកប្រាក់ថ្លៃបាយថ្ងៃត្រង់ និងប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងតាមគណនីធនាគារ ដោយសារចំនួនទឹកប្រាក់តិច ហើយកម្មករនិយោជិតដែលមានវ័យចំណាស់ត្រូវពឹងពាក់កម្មករនិយោជិតផ្សេងឱ្យជួយដក ព្រោះពួកគាត់មិនសូវចេះ។
    - ការអនុវត្តនៅក្រុមហ៊ុនផ្សេងក្នុងវិស័យកាត់ដេរដូចគ្នា គឺមានការបើកប្រាក់ឈ្នួលតាមគណនីធនាគារ ដោយឡែកប្រាក់អត្ថប្រយោជន៍ផ្សេងៗ គឺបើកដោយដៃធម្មតា។
    - យោងតាមមាត្រា ១១៣ នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ បានបញ្ជាក់អំពីការបើកប្រាក់ដោយផ្ទាល់ដៃ។
- ភាគីនិយោជកមិនអាចផ្តល់ជូនតាមការទាមទាររបស់ភាគីកម្មករនិយោជិតបានទេ ដោយមូលហេតុថា ៖
    - ដំបូងឡើយ និយោជកបានអនុវត្តបើកប្រាក់ឈ្នួលដោយផ្ទាល់ដៃ ប៉ុន្តែដោយសារមានការណែនាំពីក្រសួង និងរាជរដ្ឋាភិបាល ទើបនិយោជកអនុវត្តការបើកប្រាក់ឈ្នួលតាមប្រព័ន្ធឌីជីថល មានដូចជាធនាគារ វីង និងធនាគារ អេស៊ីលីដា ជាដើម។
    - កម្មករនិយោជិតបានស្នើសុំនិយោជកបន្ថយថ្ងៃបើកប្រាក់ថ្លៃបាយថ្ងៃត្រង់ និងប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងពីថ្ងៃសៅរ៍ មកថ្ងៃសុក្រវិញ ដោយបានលើកអំពីការលំបាក និងពេលវេលាខ្លីក្នុងការបើកប្រាក់ ហើយក្រុមហ៊ុនក៏បានព្រមព្រៀងតាមសំណើនេះរួចហើយ។

- កម្មករនិយោជិតទទួលយកការបើកប្រាក់ឈ្នួលតាមរយៈគណនីធនាគារ ចុះហេតុអ្វីបានជា សុំឱ្យនិយោជកបើកប្រាក់ថ្លៃបាយថ្ងៃត្រង់ និងប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងដោយផ្ទាល់ដៃទៅវិញ។
- ការបើកប្រាក់តាមរយៈគណនីធនាគារ គឺមានសុវត្ថិភាពជាងការបើកប្រាក់ដោយផ្ទាល់ដៃ។
- និយោជកបើកប្រាក់ថ្លៃបាយថ្ងៃត្រង់ និងប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងតាមប្រព័ន្ធធនាគារនៅរៀងរាល់ថ្ងៃសុក្រ មិនឱ្យលើសពីម៉ោង ៤រសៀលនោះទេ។

- ភាគីនិយោជកបានដាក់ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាលនូវឯកសារភស្តុតាង ដូចខាងក្រោម ៖
  - អនុសញ្ញារួមនៃការងារ រវាងសហជីពអព្យាក្រឹត្យអភិវឌ្ឍន៍សិទ្ធិការងារ ជាសមាជិកសហព័ន្ធអំណាចកម្មករខ្មែរ(KWPFU) សហជីពកម្មករកម្ពុជា ជាសមាជិកសហព័ន្ធសហជីពកម្មករកម្ពុជា(CLUF) សហជីពពលកម្មកម្ពុជា ជាសមាជិកសហព័ន្ធសហជីពពលកម្មកម្ពុជា(CFLU) ជាមួយក្រុមហ៊ុន ប៉ូវយើរ ហ្គាមេន ហ្វេកធើរី ខេមបូឌា ខមភេនី លីមីតធីត អាណត្តិទី០១ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៣ ដល់ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៦ និងមានលេខចុះបញ្ជី ០៥២ កប/អក/វក ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៣ ទទួលស្គាល់ពីក្រសួងការងារ និងបណ្តុះ-បណ្តាលវិជ្ជាជីវៈ កំណត់ថា ៖

    ***"ប្រការ៧_ ប្រាក់ឈ្នួល***

    *...*

    *ច- ការផ្តល់ប្រាក់ថ្លៃបាយថ្ងៃត្រង់*

    *... ក្រុមហ៊ុនធ្វើការបើកលុយបាយថ្ងៃត្រង់ និងលុយបាយបន្ថែមម៉ោងរៀងរាល់សប្តាហ៍ថ្ងៃសុក្រតាមប្រព័ន្ធកុំព្យូទ័រ។"*

**ហេតុផលនៃសេចក្តីសម្រេច ៖**

**ចំណុចវិវាទទី២ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកបើកប្រាក់ថ្លៃបាយថ្ងៃត្រង់ និងប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង មួយសប្តាហ៍ម្តង រៀងរាល់ថ្ងៃសុក្រ និងបើកដោយផ្ទាល់ដៃជូនកម្មករនិយោជិត**

នៅក្នុងសវនាការ ភាគីទាំងពីរទទួលស្គាល់ថា បច្ចុប្បន្ននេះ ក្រុមហ៊ុនអនុវត្តបើកប្រាក់ថ្លៃបាយថ្ងៃត្រង់ និងប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងជូនកម្មករនិយោជិត មួយសប្តាហ៍ម្តង រៀងរាល់ថ្ងៃសុក្រ តាមរយៈគណនីធនាគារ អេស៊ីលីដា។ ករណីនេះ ភាគីមិនមានវិវាទពាក់ព័ន្ធការបើកប្រាក់ថ្លៃបាយថ្ងៃត្រង់ និងប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងមួយសប្តាហ៍ម្តង នៅរៀងរាល់ថ្ងៃសុក្រនោះទេ ភាគីទាំងពីរមានវិវាទតែលើការបើកប្រាក់ថ្លៃបាយថ្ងៃត្រង់ និងប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងដោយផ្ទាល់ដៃ។

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើប្រាក់ថ្លៃបាយថ្ងៃត្រង់ និងប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង ត្រូវបើកជូនកម្មករនិយោជិតដោយផ្ទាល់ដៃដែរ ឬទេ?**

មាត្រា ១១៣ នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ចែងថា ៖ *"ប្រាក់ឈ្នួល ត្រូវបើកឱ្យផ្ទាល់ដៃទៅសាមីខ្លួនកម្មករនិយោជិត លើកលែងតែកម្មករនិយោជិតព្រមបើកតាមវិធីផ្សេងៗទៀត។ ...។"*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងលេខ ២៧៤/១៣-ស៊ិច ផ្លាស អ៊ិនដាស្ត្រី ហេតុផលនៃចំណុចវិវាទទី៩ បានបកស្រាយថា ៖ *"ប្រាក់ឈ្នួល ត្រូវបើកឱ្យផ្ទាល់ដៃ" មិនអាចធ្វើការបកស្រាយក្នុងន័យចង្អៀត ដែលសំដៅតែការបើកប្រាក់ឈ្នួលនោះ ត្រូវបើកឱ្យកម្មករនិយោជិតដោយដៃ និងដៃផ្ទាល់នោះទេ*

*ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ពាក្យនេះមានន័យថា និយោជកត្រូវមានកាតព្វកិច្ចបើកប្រាក់ឈ្នួលដោយចំពោះទៅសាមីខ្លួនកម្មករនិយោជិតតែម្តង ដោយជៀសវាងការបើកប្រាក់ឈ្នួលជំនួសសាមីខ្លួន ឬក៏បើកប្រាក់ឈ្នួលទៅឱ្យតតិយជនដែលជាម្ចាស់បំណុល ឬសាច់ញាតិណាម្នាក់ លើកលែងតែមានការឯកភាពពីសាមីកម្មករនិយោជិតនោះ ដូចមានចែងក្នុងមាត្រា ១១៣ នៃច្បាប់ការងារ ចែងថា "...លើកលែងតែកម្មករនិយោជិតព្រមបើកតាមវិធីផ្សេងៗទៀត។" (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ០៤២/១៩-បេស ស៊ីន ប៉ាវ (ខេមបូឌា) ហ្វេកជើរីឯក ហេតុផលនៃចំណុចវិវាទទី៣ និងលេខ ០២៦/២១-ខេន ស្ពត ស៊ូ ហេតុផលនៃចំណុចវិវាទទី២)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញា-កណ្តាលក្នុងសំណុំរឿងមុនៗ ខាងលើដែរ ពោលគឺនិយោជកមានកាតព្វកិច្ចបើកប្រាក់ឈ្នួលទៅឱ្យកម្មករនិយោ-ជិតសាមីដោយផ្ទាល់ ដោយជៀសវាងការបើកប្រាក់ឈ្នួលជំនួសសាមីខ្លួន ឬក៏បើកប្រាក់ឈ្នួលទៅឱ្យតតិយជនដែលជាម្ចាស់បំណុល ឬសាច់ញាតិណាម្នាក់ លើកលែងតែមានការឯកភាពពីសាមីកម្មករនិយោជិតនោះ។

យោងតាមអង្គហេតុ ភាគីកម្មករនិយោជិតបញ្ជាក់ថា និយោជកត្រូវបើកប្រាក់ថ្លៃបាយថ្ងៃត្រង់ និងប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងដោយផ្ទាល់ដៃ ដោយសំអាងលើមាត្រា ១១៣ នៃច្បាប់ស្តីពីការងារខាងលើ។ ក្រុម-ប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មាត្រា ១១៣ នៃច្បាប់ស្តីពីការងារខាងលើនេះ អនុវត្តចំពោះការបើកប្រាក់ឈ្នួល។ លើសពីនេះទៀត តាមការបកស្រាយ មាត្រា ១១៣ នៃច្បាប់ស្តីពីការងារ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការបើកប្រាក់ឈ្នួល តាមខ្លឹមសារមាត្រា ១១៣ មិនតម្រូវឱ្យត្រូវតែបើកផ្ទាល់ដៃទេ គឺបើកជូនផ្ទាល់ដល់កម្មករនិយោជិត ជៀសវាងការបើកប្រាក់ឈ្នួលជំនួសសាមីខ្លួន ឬមិនបើកប្រាក់ឈ្នួលទៅឱ្យតតិយជនដែលជាម្ចាស់បំណុល ឬសាច់ញាតិណាម្នាក់ លើកលែងតែមានការឯកភាពពីសាមីកម្មករនិយោជិតនោះ។

លើសពីនេះ មាត្រា ១០៣ នៃច្បាប់ស្តីពីការងារ ចែងថា *"ប្រាក់ឈ្នួលមានជាអាទិ៍ដូចតទៅ ៖*

- *ប្រាក់ឈ្នួលសុទ្ធសាធ*
- *ប្រាក់ម៉ោងបន្ថែម*
- *កំរៃជើងសា*
- *បុព្វលាភ និងប្រាក់បំណាច់*
- *ភាគកម្មក្នុងប្រាក់ចំណេញ*
- *ប្រាក់ដែលបើកជាផ្នូន...*

*មិនត្រូវរាប់បញ្ចូលជាមួយប្រាក់ឈ្នួល៖*

- *ការព្យាបាលសុខភាព*
- *វិភាជន៍គ្រួសារតាមច្បាប់*
- *សោហ៊ុយធ្វើដំណើរ*
- *អត្ថប្រយោជន៍ដែលផ្តល់ឱ្យ ជាពិសេសចំពោះកម្មករនិយោជិតដើម្បីសំរួលការបំពេញមុខងារ។"*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងលេខ ១៩៤/១៤-បូវយើរ ហ្គាមេន ហេតុផលនៃចំណុចវិវាទទី៨ បានយល់ឃើញថា ៖ *"ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង និងប្រាក់ថ្លៃបាយថ្ងៃត្រង់ មិនមែនជាផ្នែកមួយនៃប្រាក់ឈ្នួលទេ ប៉ុន្តែ ជាអត្ថប្រយោជន៍ដែលផ្តល់ឱ្យជាពិសេសចំពោះកម្មករនិយោជិត ដើម្បីសំរួលក្នុងការបំពេញការងារ ដូចជាប្រាក់ថ្លៃបាយធ្វើការបន្ថែម គឺផ្តល់ឱ្យកម្មករនិយោជិតសម្រាប់ទិញបាយហូប ដើម្បីឱ្យមានកម្លាំងធ្វើ*

ARBITRATION COUNCIL

*ការបន្ថែមម៉ោង។ រីឯប្រាក់ថ្លៃបាយថ្ងៃត្រង់ គឺជាអត្ថប្រយោជន៍ដែលផ្តល់ឱ្យកម្មករនិយោជិតសម្រាប់ទិញបាយហូប ដើម្បីឱ្យមានកម្លាំងបំពេញការងារនៅពេលថ្ងៃត្រង់។"*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿង ខាងលើដែរ ពោលគឺប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង និងប្រាក់ថ្លៃបាយថ្ងៃត្រង់មិនមែនជាផ្នែកមួយនៃប្រាក់ឈ្នួលទេ ប៉ុន្តែជាអត្ថប្រយោជន៍ដែលនិយោជកផ្តល់ឱ្យជាពិសេសចំពោះកម្មករនិយោជិត ដើម្បីសម្រួលក្នុងការបំពេញការងារតែប៉ុណ្ណោះ។ ហេតុនេះ ការបើកប្រាក់ឈ្នួលដែលមានចែងក្នុង មាត្រា ១១៣ នៃច្បាប់ស្តីពីការងារ មិនអនុវត្តចំពោះការបើកប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង និងប្រាក់ថ្លៃបាយថ្ងៃត្រង់នោះទេ។

បន្ថែមពីនេះ អនុសញ្ញារួមនៃការងារ រវាងសហជីពអព្យាក្រឹត្យអភិវឌ្ឍន៍សិទ្ធិការងារ ជាសមាជិកសហព័ន្ធអំណាចកម្មករខ្មែរ(KWPFU) សហជីពកម្មករកម្ពុជា ជាសមាជិកសហព័ន្ធសហជីពកម្មករកម្ពុជា (CLUF) សហជីពពលកម្មកម្ពុជា ជាសមាជិកសហព័ន្ធសហជីពពលកម្មកម្ពុជា(CFLU) ជាមួយក្រុមហ៊ុន ប៉ូវយើរ ហ្គាមេន ហ្វេកធើរី ខេមបូឌា ខមភេនី លីមីធីត អាណត្តិទី០១ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៣ ដល់ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៦ និងមានលេខចុះបញ្ជី ០៥២ កប/អក/វក ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៣ ទទួលស្គាល់ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កំណត់ថា ៖

"**ប្រការ៧_ ប្រាក់ឈ្នួល**

...

*ច- ការផ្តល់ប្រាក់ថ្លៃបាយថ្ងៃត្រង់*

*... ក្រុមហ៊ុនធ្វើការបើកលុយបាយថ្ងៃត្រង់ និងលុយបាយបន្ថែមម៉ោងរៀងរាល់សប្តាហ៍ថ្ងៃសុក្រតាមប្រព័ន្ធកុំព្យូទ័រ។"*

យោងតាមចំណុច"ច" ប្រការ៧ នៃអនុសញ្ញារួមខាងលើ និយោជកត្រូវបើកប្រាក់ថ្លៃបាយថ្ងៃត្រង់ និងប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងជូនកម្មករនិយោជិត រៀងរាល់សប្តាហ៍នៅថ្ងៃសុក្រតាមប្រព័ន្ធកុំព្យូទ័រ។ យោងតាមអង្គហេតុ និយោជកបានបើកប្រាក់ថ្លៃបាយថ្ងៃត្រង់ និងប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងជូនកម្មករនិយោជិត ដោយការផ្ទេរប្រាក់ចូលទៅក្នុងគណនីធនាគារ អេស៊ីលីដា របស់កម្មករនិយោជិតផ្ទាល់គឺ អនុវត្តស្របទៅតាមអនុសញ្ញារួមរបស់ក្រុមហ៊ុនខាងលើហើយ។

ក្រៅពីនេះ ចំពោះការលើកឡើងរបស់ភាគីកម្មករនិយោជិតដែលថា ការបើកប្រាក់ថ្លៃបាយថ្ងៃត្រង់ និងប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងដោយផ្ទាល់ដៃ គឺជួយសម្រួលដល់កម្មករនិយោជិតក្នុងការយកទៅចំណាយផ្សេងៗ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការលើកឡើងនេះពុំសមហេតុផលនោះទេ ដោយហេតុថា ការបើកដោយការផ្ទេរប្រាក់ចូលទៅក្នុងគណនីធនាគាររបស់កម្មករនិយោជិត ក៏កម្មករនិយោជិតអាចប្រើប្រាស់ក្នុងការចំណាយបានដែរ។ ភាគីកម្មករនិយោជិតក៏បានបន្ថែមទៀតថា កម្មករនិយោជិតពិបាកដកប្រាក់ថ្លៃបាយថ្ងៃត្រង់ និងប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងតាមគណនីធនាគារ ដោយសារចំនួនទឹកប្រាក់តិច ហើយកម្មករនិយោជិតដែលមានវ័យចំណាស់ ត្រូវពឹងពាក់កម្មករនិយោជិតផ្សេងឱ្យជួយដក ព្រោះពួកគាត់មិនសូវចេះ និងការអនុវត្តនៅក្រុមហ៊ុនផ្សេងក្នុងវិស័យកាត់ដេរដូចគ្នា គឺមានការបើកប្រាក់ឈ្នួលតាមគណនីធនាគារ ដោយឡែកប្រាក់អត្ថប្រយោជន៍ផ្សេងៗ គឺបើកដោយដៃធម្មតា។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការលើកឡើងនេះពុំអាចយកជាមូលដ្ឋានដើម្បីឱ្យនិយោជកអនុវត្តការបើកប្រាក់ថ្លៃបាយថ្ងៃត្រង់ និងប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងខុសពីការកំណត់នៅក្នុងអនុសញ្ញារួមនោះទេ។

យោងតាមការបកស្រាយខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកមិនមានកាតព្វកិច្ចបើកប្រាក់ថ្លៃបាយថ្ងៃត្រង់ និងប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងជូនកម្មករនិយោជិតដោយផ្ទាល់ដៃនោះទេ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកបើកប្រាក់ថ្លៃបាយថ្ងៃត្រង់ និងប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងដោយផ្ទាល់ដៃជូនកម្មករនិយោជិត។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សា-អាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ ៖

## សម្រេច និងបង្គាប់

**ចំណុចវិវាទទី២ ៖**

- បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកបើកប្រាក់ថ្លៃបាយថ្ងៃត្រង់ និងប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងដោយផ្ទាល់ដៃ ជូនកម្មករនិយោជិត។

**ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

សេចក្តីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ ចំនួន ០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរ ទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **អ៊ុំ សុទ្ធី**

ហត្ថលេខា ៖ ----------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **លីវ សុវណ្ណា**

ហត្ថលេខា ៖----------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **ម៉ែន ម៉ុនឈា**

ហត្ថលេខា ៖ ----------------------------

ARBITRATION COUNCIL